STATE OF WASHINGTON
DEPARTMENT OF SOCIAL AND HEALTH SERVICES
DIVISION OF CHILD SUPPORT (DCS)

# ការអនុញ្ញាតការដាក់ប្រាក់ដោយផ្ទាល់

## Direct Deposit Authorization

ចំពោះ៖

លេខសំណុំរឿង៖

លេខបុគ្គល៖

| | | |
|---|---|---|
| ☐ ខ្ញុំចង់បានប័ណ្ណឥណពន្ធ DCS ☐ ខ្ញុំចង់ដាក់ប្រាក់ដោយផ្ទាល់ចូលគណនាគាររបស់ខ្ញុំដែលរាយខាងក្រោម។ | | |
| នាមត្រកូល | កណ្ដាល | នាមខ្លួន |
| លេខសន្តិសុខសង្គម | ថ្ងៃខែឆ្នាំកំណើត (ខែ/ថ្ងៃ/ឆ្នាំ) | |
| អាសយដ្ឋានផ្ញើសំបុត្រ | APT. # | |
| ទីក្រុង | រដ្ឋ | កូដហ្ស៊ីប |
| លេខទូរសព្ទនៅផ្ទះ ( ) | លេខទូរសព្ទពេលថ្ងៃ ( ) | អាសយដ្ឋានអ៊ីម៉ែល (ស្រេចចិត្ត) |
| ☐ ធ្វើបច្ចុប្បន្នភាពអាសយដ្ឋានរបស់ខ្ញុំក្នុងប្រព័ន្ធជំនួយកុមារទៅជាអាសយដ្ឋានខាងលើ។ | | |
| ហត្ថលេខា (ទាមទារ) | កាលបរិច្ឆេទ | |

| | |
|---|---|
| បញ្ចូលព័ត៌មានខាងក្រោមប្រសិនបើអ្នកជ្រើសរើសដាក់ប្រាក់ដោយផ្ទាល់ទៅគណនីធនាគាររបស់អ្នក។ ភ្ជាប់សែកដែលចាត់ទុកជាមោឃៈ។ | |
| ឈ្មោះធនាគារ | លេខទូរសព្ទសាខាធនាគារ ( ) |
| លេខផ្លូវធនាគារ | លេខគណនីធនាគារ ☐ សែក ☐ គណនីសន្សំ |
| ប្រសិនបើអ្នកសំណួរអំពីការដាក់ដោយផ្ទាល់ ឬប័ណ្ណឥណពន្ធ DCS ទូរសព្ទទៅ 800-468-7422។ | |

ផ្ញើសំបុត្រទៅ៖

DIVISION OF CHILD SUPPORT
EFT DISBURSEMENTS
PO BOX 9010
OLYMPIA WA 98507-9010
ឬទូរសារទៅលេខ៖ 360-664-5109

0099999985000000000000000000023250

គ្មានបុគ្គលណាមួយព្រោះតែពូជសាសន៍ ពណ៌សម្បុរ ដើមកំណើត ជំនឿ សាសនា ភេទ អាយុ ឬពិការភាព នឹងត្រូវរើសអើងប្រឆាំងក្នុងការងារ សេវាកម្ម ឬផ្នែកណាមួយនៃសកម្មកម្មវិធី។ ទម្រង់បែបបទនេះគឺអាចរកបានក្នុងទម្រង់ជំនួយតាមការស្នើសុំ។

ការបញ្ចេញព័ត៌មានមុនពេលទិញកាត ReliaCard® របស់ U.S. Bank
ឈ្មោះកម្មវិធី៖ Washington Division of Child Support
(ផ្នែកគាំពារកុមាររបស់ទីក្រុងវ៉ាស៊ីនតោន)

សេវានានាអាចរកបានជាភាសាអង់គ្លេសតែប៉ុណ្ណោះ។

| ថ្លៃសេវាប្រចាំខែ | ក្នុងការជាវម្ដង | ការដកប្រាក់ពី ATM | ការបញ្ចូលសាច់ប្រាក់ |
|---|---|---|---|
| **$0** | **$0** | **$0** ក្នុងបណ្ដាញ<br>**$0.99*** ក្រៅបណ្ដាញ | **N/A** |

| | |
|---|---|
| ការសាកសួរសមតុល្យតាម ATM<br>(ខាងក្នុង ឬខាងក្រៅបណ្ដាញ) | $0 |
| សេវាបម្រើអតិថិជន<br>(ភ្នាក់ងារស្វ័យប្រវត្តិ ឬដោយផ្ទាល់) | $0 ក្នុងការទូរសព្ទមួយលើក |
| អសកម្មភាព | $0 |

**យើងគិតថ្លៃសេវា 3 ប្រភេទផ្សេងទៀត។** នេះគឺជាថ្លៃសេវាមួយចំនួន៖

| | |
|---|---|
| ប្រតិបត្តិការអន្តរជាតិ | 2% |
| ការដូរយកកាតថ្មី<br>(ការដឹកជញ្ជូនស្ដង់ដារ ឬឆាប់រហ័ស) | $0 ឬ $15.00 |

* ថ្លៃសេវានេះអាចទាបជាងនេះ អាស្រ័យលើរបៀប និងកន្លែងដែលកាតនេះត្រូវបានប្រើប្រាស់។

**មិនមានលក្ខណៈពិសេសនៃការដកប្រាក់លើសសមតុល្យ/ឥណទាននោះទេ។** ទឹកប្រាក់របស់អ្នកមានសិទ្ធិទទួលបានធានារ៉ាប់រងពី FDIC។

សម្រាប់ព័ត៌មានទូទៅអំពីគណនីបង់ប្រាក់ទុកជាមុន សូមចូលទៅកាន់ *cfpb.gov/prepaid* (ជាភាសាអង់គ្លេស)។ សូមស្វែងរកព័ត៌មានលម្អិត និងលក្ខខណ្ឌនានាសម្រាប់ថ្លៃ និងសេវាទាំងអស់ក្នុងកញ្ចប់កាត ឬទូរសព្ទទៅលេខ **1-866-363-4136** ឬចូលទៅកាន់ **usbankreliacard.com** (ជាភាសាអង់គ្លេស)។

| ថ្លៃសេវាទាំងអស់ | ចំនួន | ព័ត៌មានលម្អិត |
|---|---|---|
| **ទទួលសាច់ប្រាក់** | | |
| ការដកប្រាក់ពី ATM (ក្នុងបណ្តាញ) | $0 | នេះគឺជាថ្លៃសេវារបស់យើងក្នុងការដកប្រាក់ម្តង ។ "ក្នុងបណ្តាញ" សំដៅទៅលើបណ្តាញ ATM របស់ U.S. Bank ឬ MoneyPass®។ ទីតាំងអាចរកឃើញនៅគេហទំព័រ *usbank.com/locations* (ជាភាសាអង់គ្លេស) ឬ *moneypass.com/atm-locator.html* (ជាភាសាអង់គ្លេស)។ |
| ការដកប្រាក់ពី ATM (ក្រៅបណ្តាញ) | $0.99 | នេះគឺជាថ្លៃសេវារបស់យើងក្នុងការដកប្រាក់ម្តង ។ ថ្លៃសេវានេះត្រូវបានលើកលែងសម្រាប់ការដកប្រាក់ចេញពី ATM ចំនួន 2 លើកដំបូងរបស់អ្នកពីការដកប្រាក់ម្តង ដែលរួមបញ្ចូលទាំងការដកប្រាក់ចេញពី ATM (នៅក្រៅបណ្តាញ) និងការដកប្រាក់ពី ATM នៅក្រៅប្រទេស។ "ក្រៅបណ្តាញ" សំដៅទៅលើម៉ាស៊ីន ATM ទាំងអស់នៅក្រៅបណ្តាញរបស់ U.S. Bank ឬរបស់ MoneyPass។ អ្នកក៏អាចត្រូវបានប្រតិបត្តិកររបស់ម៉ាស៊ីន ATM គិតថ្លៃសេវាផងដែរ សូម្បីតែអ្នកមិនបានបញ្ចប់ប្រតិបត្តិការក៏ដោយ។ |
| ការដកសាច់ប្រាក់ពីបុគ្គលិកធនាគារ | $0 | នេះគឺជាថ្លៃសេវារបស់យើងសម្រាប់ពេលដែលអ្នកដកសាច់ប្រាក់ចេញពីកាតរបស់អ្នកជាមួយបុគ្គលិកធនាគារនៅឯធនាគារ ឬនៅឯសហជីពឥណទានដែលទទួលយក Visa®។ |
| **ការប្រើប្រាស់កាតរបស់អ្នកនៅខាងក្រៅសហរដ្ឋអាមេរិក** | | |
| ប្រតិបត្តិការអន្តរជាតិ | 2% | នេះគឺជាថ្លៃសេវារបស់យើង ដែលត្រូវអនុវត្តនៅពេលដែលអ្នកប្រើប្រាស់កាតរបស់អ្នកសម្រាប់ការទិញពីពាណិជ្ជករនៅ ក្រៅប្រទេស ឬសម្រាប់ការដកសាច់ប្រាក់ពីម៉ាស៊ីន ATM នៅក្រៅប្រទេស ហើយគឺជាចំនួនភាគរយមួយនៃចំនួនទឹកប្រាក់នៅក្នុងប្រតិបត្តិការជាដុល្លារ បន្ទាប់ពីការប្តូររូបិយប័ណ្ណណាមួយ។ ប្រតិបត្តិការមួយចំនួនត្រូវបានចាត់ទុកថា ជាប្រតិបត្តិការផ្ទេរប្រាក់នៅក្រៅប្រទេសនៅក្រោមច្បាប់បណ្តាញដែលអាចអនុវត្តបាន ទោះបីជាអ្នក និង/ពាណិជ្ជករ ឬ ATM មានទីតាំងនៅក្នុងសហរដ្ឋអាមេរិកក៏ដោយ ហើយយើងមិនគ្រប់គ្រងពីរបៀបដែលពាណិជ្ជករ ATM និងប្រតិបត្តិការទាំងនេះត្រូវបានគេចែកចំណាត់ថ្នាក់នោះឡើយសម្រាប់គោលបំណងនេះ។ |

| | | |
|---|---|---|
| ការដកប្រាក់ពីម៉ាស៊ីន ATM អន្តរជាតិ | $0.99 | នេះគឺជាថ្លៃសេវារបស់យើងក្នុងការដកប្រាក់ម្តង។ ថ្លៃសេវានេះត្រូវបានលើកលែងសម្រាប់ការដកប្រាក់ចេញពី ATM ចំនួន 2 លើកដំបូងរបស់អ្នកពីការដកប្រាក់ម្តង ដែលរួមបញ្ចូលទាំងការដកប្រាក់ចេញពី ATM (នៅក្រៅបណ្តាញ) និង ការដកប្រាក់ពី ATM នៅក្រៅប្រទេស។ អ្នកក៏អាចត្រូវបានប្រតិបត្តិកររបស់ម៉ាស៊ីន ATM គិតថ្លៃសេវាផងដែរ សូម្បីតែ អ្នកមិនបានបញ្ចប់ប្រតិបត្តិការក៏ដោយ។ |
| **ផ្សេងៗ** | | |
| ការដូរយកកាតថ្មី | $0 | នេះគឺជាថ្លៃសេវារបស់យើងក្នុងការដូរយកកាតថ្មី ដែលនឹងត្រូវផ្ញើទៅកាន់អ្នកតាមប្រៃសណីយ៍ក្នុងការដឹកជញ្ជូនតាមស្តង់ដារ (ដល់ទៅ 10 ថ្ងៃនៃថ្ងៃធ្វើការ)។ |
| ការដឹកជញ្ជូនរហ័សសម្រាប់ការដូរយកកាតថ្មី | $15.00 | នេះគឺជាថ្លៃសេវារបស់យើងសម្រាប់ការដឹកជញ្ជូនឆាប់រហ័ស (ដល់ទៅ 3 ថ្ងៃនៃថ្ងៃធ្វើការ) ដែលត្រូវគិតបន្ថែមពីលើថ្លៃសេវាដូរកាតថ្មីណាមួយ ។ |

ខណៈដែលការផ្សព្វផ្សាយនេះត្រូវបានផ្តល់ជូនជាភាសាខ្មែរ បន្ទាប់ពីការផ្សព្វផ្សាយរបស់ U.S. Bank និងឯកសារពាក់ព័ន្ធទៅនឹងកិច្ចព្រមព្រៀងក្នុងកិច្ចសន្យារបស់អ្នកការបញ្ចេញ ព័ត៌មានសេចក្តីជូនដំណឹង និងរបាយការណ៍ សេវាធនាគារនៅលើទូរសព្ទចល័ត និងតាមប្រព័ន្ធអ៊ីនធឺណិតអាចរកបានត្រឹមតែជាភាសាអង់គ្លេសប៉ុណ្ណោះ។ អ្នកត្រូវតែអាចអាន និងយល់ឯកសារទាំងនេះ ឬមានជំនួយក្នុងការបកប្រែឯកសារទាំងនេះ ដើម្បីយល់ និងប្រើប្រាស់ផលិតផល ឬសេវានេះ។ ឯកសារជាភាសាអង់គ្លេសអាចរកបានតាមការស្នើសុំ។

ទឹកប្រាក់របស់អ្នកមានសិទ្ធិទទួលបានធានារ៉ាប់រងពី FDIC។ ទឹកប្រាក់របស់អ្នកនឹងត្រូវបានរក្សាទុកនៅឯ U.S. Bank National Association ដែលជាស្ថាប័នក្រោមការធានារ៉ាប់រងរបស់ FDIC និងត្រូវបានធានារ៉ាប់រងទឹកប្រាក់រហូតដល់ $250,000 តាមរយៈ FDIC ក្នុងករណីដែល U.S. Bank បរាជ័យ។ សូមមើលនៅ *fdic.gov/deposit/deposits/prepaid.html* (ជាភាសាអង់គ្លេស) សម្រាប់ព័ត៌មានលម្អិត។

មិនមានលក្ខណៈពិសេសនៃការដកប្រាក់លើសសមតុល្យ/ឥណទាននោះទេ។

សូមទាក់ទងទៅកាន់សេវាបម្រើម្ចាស់កាតតាមរយៈការទូរសព្ទទៅលេខ **1-866-363-4136** ឬតាមសំបុត្រទៅកាន់អាសយដ្ឋាន P.O. Box 551617, Jacksonville, FL 32255 ឬចូល ទៅកាន់ ***usbankreliacard.com*** (ជាភាសាអង់គ្លេស)។

សម្រាប់ព័ត៌មានទូទៅអំពីគណនីបង់ប្រាក់ទុកជាមុន សូមចូលទៅកាន់ *cfpb.gov/prepaid* (ជាភាសាអង់គ្លេស)។ ប្រសិនបើអ្នកមានពាក្យបណ្តឹងអំពីគណនីបង់ប្រាក់ទុកជាមុន សូមទូរសព្ទមកកាន់ការិយាល័យការពារហិរញ្ញវត្ថុរបស់អ្នកប្រើប្រាស់ (Consumer Financial Protection Bureau) តាមលេខ 1-855-411-2372 ឬចូលទៅកាន់ *cfpb.gov/complaint* (ជាភាសាអង់គ្លេស)។

CR-54805338 – Cambodian

កាត ReliaCard ចេញដោយ U.S. Bank National Association អនុលោមតាមអាជ្ញាប័ណ្ណពីក្រុមហ៊ុន Visa U.S.A. Inc. © 2023 U.S. Bank ។ Member FDIC.